# ស្ថានទូតជប៉ុន
# ប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

លេខ.40 PR-19/EoJ　　　　　　　　　　ថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩

## <u>ជប៉ុនផ្តល់ ៣១០,៧៧៧ ដុល្លារអាមេរិក</u>
## <u>សម្រាប់គម្រោងលើកកម្ពស់ការអប់រំបរិយាប័ន្ន ក្នុងខេត្តកណ្តាល</u>

រដ្ឋាភិបាលជប៉ុន បានឯកភាពផ្តល់ថវិកាសរុបចំនួន ៣១០,៧៧៧ ដុល្លារអាមេរិក ដល់អង្គការ សមាគមសម្រាប់ជំនួយ និងសង្គ្រោះនៃប្រទេសជប៉ុន (AAR Japan) ក្រោមគ្រោងការណ៍ជំនួយឧបត្ថម្ភឥតសំណង សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយឯកឧត្តម ហ្វូរីណូអ៊ុជិ ហ៊ីដេហ៊ីសា ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោកស្រី MUKAI Satomi នាយិកាស្តីទីប្រចាំប្រទេសនៃអង្គការ AAR Japan សម្រាប់គម្រោង "លើកកម្ពស់ការអប់រំបរិយាប័ន្នសម្រាប់កុមារពិការ តាមរយៈពង្រឹងការអនុវត្តក្នុងតំបន់គំរូ និងការអភិវឌ្ឍប្រព័ន្ធវាយតម្លៃការអប់រំបរិយាប័ន្ន"។

នៅក្នុងគម្រោងនេះ AAR Japan នឹងបង្កើតនូវប្រព័ន្ធវាយតម្លៃលើការអនុវត្តការអប់រំបរិយាប័ន្ននិងអនុវត្តសកម្មភាពដើម្បីគាំទ្រដល់ការបង្កើនសមត្ថភាពរបស់គណៈកម្មការគាំទ្រជនពិការថ្នាក់រដ្ឋបាលឃុំ។ តាមរយៈគម្រោងនេះបរិយាកាសសិក្សានិងគុណភាពនៃការអប់រំសម្រាប់កុមារដែលមានពិការភាពនឹងត្រូវបានកែលម្អ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពអង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាជាង៣៦លានដុល្លារអាមេរិក ដល់គម្រោងចំនួន១១៨ ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសម្អាតមីនក្នុងប្រទេសកម្ពុជា។

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣១០*
*អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp*
*គេហទំព័រ៖ http://www.kh.emb-japan.go.jp*

សុន្ទរកថារបស់ **ឯកឧត្តម ហ្សីរ៉ូណូ អ៊ុជិ ហ៊ីដេហ៊ីសា**
ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជាថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយក្នុងគម្រោងឧបត្ថម្ភឥតសំណងសម្រាប់អង្គការក្រៅរដ្ឋាភិបាលជប៉ុន។
២ សីហា ២០១៩

- សូមគោរពឯកឧត្តម ជា ជាតិ អនុរដ្ឋលេខាធិការ នៃក្រសួងអប់រំ យុវជន និង កីឡា
- សូមគោរពឯកឧត្តម គីម រិទ្ធី អនុអភិបាលនៃគណៈអភិបាលខេត្តកណ្តាល
- សូមគោរពលោកស្រី Satomi Mukai នាយិកាស្តីទីប្រចាំប្រទេស នៃអង្គការ AAR Japan
- សូមគោរពភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលបានរៀបចំពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយក្នុងគម្រោងឧបត្ថម្ភឥតសំណងសម្រាប់អង្គការក្រៅរដ្ឋាភិបាលជប៉ុន។

ខ្ញុំសូមជំរាបជូនអំពីគម្រោងដែលបានចុះហត្ថលេខានាថ្ងៃនេះដូចតទៅ:

រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាប្រមាណ ៣១០,០០០ ដុល្លារអាមេរិក ដល់អង្គការ AAR Japan។ អង្គការនេះនឹងខិតខំដើម្បីផ្សព្វផ្សាយ "ការអប់រំបរិយាបន្ន" នៅទូទាំងប្រទេស ដែលអាចធ្វើឲ្យកុមាររៀនជាមួយគ្នាដោយមិនគិតពីពិការភាពនិងអនុវត្តសកម្មភាពដើម្បីគាំទ្រដល់ការបង្កើនសមត្ថភាពរបស់ "គណៈកម្មការគាំទ្រជនពិការថ្នាក់រដ្ឋបាលឃុំ" ដែលជាអង្គការសាធារណៈ។

តាមរយៈគម្រោងនេះ ខ្ញុំរំពឹងថាប្រជាជននឹងយល់ពីតម្លៃនៃការអប់រំបរិយាបន្ន កាន់តែស៊ីជម្រៅហើយបរិយាកាសសិក្សាសម្រាប់សិស្សដែលមានពិការភាពនៅកម្ពុជានឹងត្រូវបានកែលម្អ។

ជាទីបញ្ចប់ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី សូមមានសុខភាពល្អ សុភមង្គល និង សូមឲ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន។

សូមអរគុណ។